ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០១៩ ព.ណ.កណប.ប្រក

# ប្រកាស
## ស្ដីពី
## ការកំណត់លក្ខណៈសម្បត្តិថេយន្តថ្មី

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៧ សរណន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខណៈសម្បត្តិរថយន្តថ្មី ដើម្បីជានាការអនុវត្តសិទ្ធិផ្តាច់មុខដោយស្មើភាព និងស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ២ ._**

លក្ខណៈសម្បត្តិរថយន្តថ្មី ត្រូវបានកំណត់ ដូចខាងក្រោម៖

១. ត្រូវមានរយៈចម្ងាយនៃការប្រើប្រាស់មិនលើសពី ៥ ០០០ គីឡូម៉ែត្រ ក្នុងកញ្ចក់ម៉ែត្ររថយន្ត និង

២. ត្រូវមានឆ្នាំម៉ូដែលរបស់រថយន្ត ក្នុងឆ្នាំបច្ចុប្បន្ន (N) ឬឆ្នាំម៉ូដែលមុនមួយឆ្នាំ (N-1) ឬក្រោយមួយឆ្នាំ (N+1) និង

៣. មិនត្រូវបានលក់ ឬជួលលើកដំបូងបង្អស់ពីក្រុមហ៊ុនផលិតរថយន្ត ក្រុមហ៊ុននាំចូលរថយន្ត ក្រុមហ៊ុនចែកចាយ ឬលក់រថយន្ត ឬភ្នាក់ងាររបស់ក្រុមហ៊ុនទាំងអស់នេះទៅឱ្យអ្នកប្រើប្រាស់។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៤

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh